# តើនយោបាយគ្រួសារតាក់ស៊ីនចាញ់បារមីកម្ពុជាឬ?

លោកថាក់ស៊ីនស៊ីណាវ៉ាត្រាគឺជាអ្នកនយោបាយដ៏មានឥទ្ធិពលម្នាក់នៅក្នុងប្រទេសថៃលោកបានចូលកាន់តំណែងជានាយករដ្ឋមន្ត្រីថៃកាលពីឆ្នាំ២០០១ក្រោយពីទទួលបានសំលេងគាំទ្រយ៉ាងច្រើនៗក្នុងរយៈពេល៤ឆ្នាំនៃអាណត្តិរបស់ខ្លួនលោកថាក់ស៊ីនបាននាំសង្គមថៃឱ្យរីកត្រដែតឡើងក្នុងផាកអន្តរជាតិ និងបន្តទទួលបានការសទរពីពលរដ្ឋថៃពេញប្រទេស។ ភស្តុតាងមួយដែលមិនអាចប្រកែកបានគឺលោកបានជាប់ឆ្នោត២អាណត្តិជាប់គ្នាតែម្តងពោលគឺនៅឆ្នាំ២០០១ដល់២០០៤ហើយជាប់ឆ្នោតបន្តដឹកនាំប្រទេសថៃក្នុងអាណត្តិបន្ទាប់ដោយទទួលលទ្ធផលយ៉ាងភ្លូកទឹកភ្លូកដីនៅអាណត្តិទី២នៅឆ្នាំ២០០៥។ គេមើលឃើញថាក្នុងសង្គមថៃលោកថាក់ស៊ីនជានាយករដ្ឋមន្ត្រីដែលជាប់ឆ្នោតទី១ដែលបានកាន់តំណែងពេញអាណត្តិ៤ឆ្នាំ ព្រោះថាកន្លងមកនៅប្រទេសថៃនាយករដ្ឋមន្ត្រីភាគច្រើនដែលឡើងកាន់តំណែងដោយរដ្ឋប្រហារ។

ក៏ប៉ុន្តែនៅក្នុងអាណត្តិទី២លោកកាន់តំណែងបានតែជាង១ឆ្នាំប៉ុណ្ណោះលោកក៏ត្រូវបានគេធ្វើរដ្ឋប្រហារទំលាក់លោកចេញពីតំណែងស្របពេលលោកកំពុងបំពេញបេសកម្មនៅក្រៅប្រទេស។ បើយើងសរុបទាំងពីរអាណត្តិលោកកាន់តំណែងបាន៥ឆ្នាំ៧ខែនិង១០ថ្ងៃគត់[1]។

បើទោះបីលោកថាក់ស៊ីនត្រូវបានគេធ្វើរដ្ឋប្រហារក្តី ក៏ស្រមោលរបស់លោកហាក់នៅបន្តចាក់ជ្រៅក្នុងនយោបាយថៃដដែល។ការណ៍នេះរំលេចឱ្យឃើញតាមរយៈការឈានជើងចូលក្នុនយោបាយរបស់សមាជិកគ្រួសារលោកថាក់ស៊ីនជាបន្តបន្ទាប់ រួមានមប្អូនស្រី,ប្អូនថ្លៃ,កូនស្រី និងមនុស្សជំនិតៗរបស់គាត់ជាដើម។

1 Hughes, Caroline. “Cambodia and Thailand: Diplomacy, Nationalism and the Border Conflict.” Contemporary Southeast Asia, vol. 25, no. 3, 2003, pp. 456–478.

ជាក់ស្តែងប្អូនស្រីករបស់លោកថាក់ស៊ីន គឺលោកស្រីយីងឡាក់បានក្លាយជានាយករដ្ឋមន្ត្រីក្នុងឆ្នាំ២០១១-២០១៤ រីឯពេលបច្ចុប្បន្ននេះ(២០២៥)កូនស្រីរបស់លោកថាក់ស៊ីន គឺលោកស្រី ផែ ថងថាន កំពុងមានតំណែងជានាយករដ្ឋមន្ត្រីផងដែរ។ ភស្តុតាងទាំងនេះហើយដែលយើងអាចនិយាយបានថាគ្រួសារលោកថាក់ស៊ីនគឺជាគ្រួសារដែលមានឥទ្ធិពលនៅក្នុងសង្គមថៃនារយៈពេល២៥ឆ្នាំចុងក្រោយនេះ។ ជាមួយគ្នានេះអ្វីដែលជាការកត់សម្គាល់នោះគឺថាអំឡុងពេលដែលសាច់ញាតិគ្រួសារលោកថាក់ស៊ីនកាន់តំណែងជានាយករដ្ឋមន្ត្រីគឺគេតែងសង្កេតឃើញមានការឡើងកំដៅលើបញ្ហាទំនាក់ទំនងកម្ពុជាថៃជានិច្ចដែលក្នុងនោះគេសង្កេតឃើញមានភាពប្រទាក់ក្រឡាគ្នាម្តងហើយម្តងទៀតជាមួយនឹងបញ្ហារសើបនៃទំនាក់ទំនងកម្ពុជា-ថៃក្នុងអាណត្តិសំខាន់ៗចំនួនបីដង ដែលបានបង្កឱ្យមានភាពតានតឹងផ្នែកនយោបាយទាំងអំឡុងពេលលោកថាក់ស៊ីននិងគ្រួសាររបស់គាត់ មានដូចជា ទី១.ពេលលោកថាក់ស៊ីនជានាយករដ្ឋមន្ត្រី មានចលនាជាតិនិយមមួយនៅឆ្នាំ២០០៣កាលនោះនាំឱ្យមានកុបកម្មនៅទីក្រុងភ្នំពេញដុតស្ថានទូតថៃ, ទី២.ជុំវិញបញ្ហាជម្លោះប្រាសាទព្រះវិហារក្រោមការដឹកនាំរបស់លោកស្រីយីងឡាក់ដែលជាប្អូនស្រីនិងវិបត្តិព្រំដែនដែលកំពុងបន្តនៅឆ្នាំ២០២៥នេះ ដែលជាការកាន់តំណែងរបស់លោកស្រី Paetongtarn ជាកូនរបស់លោកថាក់ស៊ីន។

ក្នុងន័យដដែលនេះយើងនឹងពិនិត្យមើលស្ថានការណ៍នយោបាយនិងការវិវត្តនានាជុំវិញទំនាក់ទំនងកម្ពុជាថៃពីឆ្នាំ២០០៣ដល់ឆ្នាំ២០២៥ដោយរំលេចតែក្នុងអំឡុងពេលកាន់តំណែងដោយគ្រួសារលោកថាក់ស៊ីនស៊ីណាវ៉ាត្រាដើម្បីយកមកបង្ហាញជាកម្មវត្ថុសិក្សាតែប៉ុណ្ណោះ, ជាមួយគ្នានេះយើងនឹងផ្តោតលើទិដ្ឋភាពពីរបៀបដែលនយោបាយរាជានិយមនិងជាតិនិយមនៃនយោបាយផ្ទៃក្នុងថៃ ថាតើហេតុអ្វីបានជារាល់ពេលដែលគ្រួសារលោកថាក់ស៊ីនដឹកនាំសង្គមថៃ ម្តេចបានជាមានកំហឹងជាតិនិយមជ្រុលខ្លាំងម្ល៉េះរវាងកម្ពុជានឹងប្រទេសថៃ? ហើយរាល់ពេលដែលប៉ះទង្គិចជាមួយកម្ពុជារួចតើជោគវាសនានាយករដ្ឋមន្ត្រីរបស់ថៃនឹងទៅជាយ៉ាងណា?

## ១. នយោបាយជាតិនិយមរបស់លោកថាក់ស៊ីនស៊ីណាវ៉ាត្រា និងវិបត្តិជាមួយកម្ពុជាឆ្នាំ២០០៣

នៅខែមករា ឆ្នាំ២០០៣ ទីក្រុងភ្នំពេញបានផ្ទុះឡើងក្នុងកុប្បកម្មបន្ទាប់ពីកាសែតនៅកម្ពុជាមួយបានរាយការណ៍ដោយស្រង់សម្តីតារាសម្តែងថៃនាង ស៊ូវ៉ាន់ណេត (Suvanant Kongying, ដែលពលរដ្ឋខ្មែរភាគច្រើនបានស្គាល់ថានាងផ្កាយព្រឹក)បានអះអាងថា ប្រាសាទអង្គរវត្តជារបស់ប្រទេសថៃ ហើយកម្ពុជាបានយកប្រាសាទអង្គរវត្តពីថៃ[1] ក្នុងនោះកាសែតដេលីលីនិងវិទ្យុបានរាយការណ៍ថា ស៊ូវ៉ាន់ណេត បាននិយាយក្នុងបទសម្ភាសមិនជាក់លាក់មួយថា «ប្រសិនបើអ្នកឧបត្ថម្ភ ឬអ្នកផ្សព្វផ្សាយណាមួយអញ្ជើញខ្ញុំមកលេងឬសម្តែងនៅកម្ពុជា ប្រជាជនកម្ពុជាត្រូវតែយល់ព្រមប្រគល់ប្រាសាទអង្គរមកខ្ញុំវិញ»[2]។នេះជាដើមចមដែលនាំឱ្យស្ថានភាពនៃទំនាក់ទំនងកម្ពុជាថៃនាពេលនោះមានភាពតានតឹងខ្លាំងដែលហាក់ជារបត់ថ្មីមួយក្នុងរង្វង់ទំនាក់ទំនងកម្ពុជាថៃ។ កំហឹងជាតិនិយមបានផ្ទុះឡើងខ្លាំងនៅកម្ពុជា ដោយរាប់តាំងពីមហាជនទូទៅរហូតរហូតដល់កម្រិតថ្នាក់ដឹកនាំ។ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាបានមានប្រសាសន៍ជាតិនិយមធ្ងន់ៗតបទៅនឹងពាក្យសម្តីរបស់នាងផ្កាយព្រឹកវិញថា«តម្លៃខ្លួនរបស់នាងមិនបានស្មើនឹងស្មៅមួយទងនៅអង្គរវត្តផង....[3] »។ កំហឹងជាតិនិយមកាន់តែពុះកញ្ជ្រោលឡើងៗពិសេសក្រោយពេលមានពត៌មានចចាមអារាមមកថាស្ថានទូតខ្មែរនៅក្រុងបាំងកកត្រូវបានដុតបំផ្លាញ[4]។

1.The Independent. “The Actress, the Temple, and the Alleged Remark That Brought Two Nations to the Brink of War.” The Independent, 31 January 2003. https://www.independent.co.uk/news/world/asia/the-actress-the-temple-and-the-alleged-remark-that-brought-two-nations-to-the-brink-of-war-5352428.html. Accessed June 16, 2025.

2.DAWN. “Cambodians Attack Thai Embassy.” DAWN, January 30, 2003. https://www.dawn.com/news/79958/cambodians-attack-thai-embassy. Accessed June 17, 2025.

3. Paddock, Richard C. “Rumor of Thai Actress’ Words Salted a Wound.” Los Angeles Times, February 3, 2003. https://www.latimes.com/archives/la-xpm-2003-feb-03-fg-cambo3-story.html. Accessed June 17, 2025.

4.Daniel Malloy.“13 Years Have Passed: My Escape From Phnom Penh.”Linkedin, December 14, 2016. https://www.linkedin.com/pulse/13-years-have-passed-my-escape-from-phnom-penh-pavin-chachavalpongpun. Accessed June 17, 2025.

តំណើងនេះបានរុញកំហឹងនេះបានជំរុញឱ្យមហាជននៅភ្នំពេញផ្ទុះកំហឹងឡើងខ្លាំង ហើយក៏ឈានដល់កុប្បមកម្មបំផ្លិចបំផ្លាញអាជីវកម្មថៃមួយចំនួនទៀតរួមទាំង Royal Phnom Penh Hotel និងផុតស្ថានទូតថៃប្រចាំទីក្រុងភ្នំពេញថែមទៀតផងនាថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣។ ក្រោយហេតុការណ៍នោះបានបណ្តាលឱ្យទំនាក់ទំនងប្រទេសទាំងពីរហាក់ដើរដល់ផ្លូវទល់ច្រក ដោយទំនាក់ទំនងការទូតកម្ពុជា-ថៃឈានដល់ភាពតានតឹងបំផុត ទំនាក់ទំនងការទូតត្រូវបានផ្អាកនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០០៣ ។ ទាំងផ្លូវចរាចរណ៍ អាកាសចរណ៍ ទេសចរណ៍និងពាណិជ្ជកម្មនានាត្រូវបានបានបញ្ឈប់ ហើយអាជ្ញាធរថៃបានប្រាប់ពលរដ្ឋថៃត្រូវបានណែនាំឲ្យចៀសវាងការធ្វើដំណើរមកកម្ពុជា ទន្ទឹមនឹងនេះអាជ្ញាធរកម្ពុជាបានរឹតបន្តឹងការចូលរបស់ថៃក្នុងតំបន់មួយចំនួនដូចជាខេត្តសៀមរាបនិងបន្ទាយមានជ័យផងដែរ។ ថៃបានបណ្តេញទូតខ្មែរប្រចាំបាំងកកហើយជាការឆ្លើយតបមកវិញកម្ពុជាក៏បានបណ្តេញទូតថៃប្រចាំទីក្រុងភ្នំពេញដូចគ្នាដែរ [1]។ ក្រៅពីសកម្មភាព ការទូត និងពាណិជ្ជកម្មភាគីថៃក៏បានបញ្ជូននាវាចម្បាំងមួយគ្រឿងនិងនាវាល្បាតបួនគ្រឿងមកគៀកនិងដែនទឹកកម្ពុជាហើយភាគីថៃបានដាក់ពង្រាយកងកម្លាំងរបស់ខ្លួននៅតាមច្រកព្រំដែនកម្ពុជា-ថៃ។ កងកម្លាំងថៃដែលបានដាក់ពង្រាយនៅតាមច្រកព្រំដែនគឺមកពីក្រុម (Thai-110 Special forces) ដូចនេះភាគីកម្ពុជាបានប្រកាសបិទព្រំដែនកម្ពុជា-ថៃ។ ការបិទព្រំដែនកម្ពុជា-ថៃ បានធ្វើឱ្យផលិតផលថៃជាង ១ពាន់មុខមិនអាចចូលមកកម្ពុជាបាននោះទេ ដូចនេះការជួញដូរមុខទំនិញរវាងកម្ពុជា-ថៃ បានរាំងស្ទះកកកុញពេញច្រកព្រំដែន ។ សេនារីយោនយោបាយជាតិនិយមនេះ ហាក់ត្រូវបានពលរដ្ឋប្រទេសទាំងសងខាងគាំទ្រដំហររដ្ឋាភិបាលរៀងៗខ្លួន និងស្របតាមសភាពការណ៍នេះ គេសង្កេតឃើញថា ជាយុទ្ធសាស្ត្ររបស់អ្នកនយោបាយកំពូលប្រទេសទាំងពីរដើម្បីទាញចំណេញខាងទិដ្ឋភាពនយោបាយរៀងៗខ្លួន ។

1 Aglionby, John. "Thais Cut Links with Cambodia after Riots." The Guardian, January 31, 2003. https://www.theguardian.com/world/2003/jan/31/cambodia. Accessed June 17, 2025.

ក្នុងឆ្នាំ២០០៣កម្ពុជានឹងនាមានការបោះឆ្នោតថ្នាក់ជាតិមួយនៅខែកក្កដា វាស្របពេលដែលនយោបាយផ្ទៃក្នុងកម្ពុជានាពេលនោះហាក់មានភាពមិនសូវរលូនប៉ុន្មានដែរ រវាងគណបក្សប្រជាជនកម្ពុជានិងគណបក្សហ្វុនស៊ិនប៉ិច [1]។ ការណ៍នេះនាំឱ្យគេយល់ថាសេនារីយោជាតិនិយមក៏ជាការទាក់ទាញចំណេញខាងទិដ្ឋភាពនយោបាយខ្លះផងដែរ។ ចំពោះប្រទេសថៃវិញ ក្នុងឆ្នាំ២០០៣ជាពេលដែលលោកថាក់ស៊ីនដឹកនាំប្រទេសថៃបានពាក់កណ្តាលអាណត្តិ (២០០១-២០០៥) ព្រោះនៅសង្គមថៃអាណត្តិនាយករដ្ឋមន្ត្រី គឺមានតែ៤ឆ្នាំប៉ុណ្ណោះ។ ការណ៍នេះដើម្បីទាញយកប្រជាប្រិយភាពសម្រាប់ការបោះឆ្នោតនៅអាណត្តិបន្ទាប់លោកថាក់ស៊ីនបានប្រើគោលនយោបាយទាក់ទាញយ៉ាងច្រើនដែលយើងអាចមើលឃើញដូចខាងក្រោម៖

### ១.១. បរិយាកាសនយោបាយនិងនិន្នាការសង្គមថៃនៅឆ្នាំ២០០៣

គេមើលឃើញថា លោកថាក់ស៊ីន ស៊ីណាវ៉ាត្រាបានទាក់ទាញអ្នកគាំទ្រដើម្បីរក្សាអំណាចខ្លួនដោយអនុវត្តគោលនយោបាយប្រជានិយមដែលមានដូចជាគោលនយោបាយថៃទាំសុខភាពសកល៣០បាត,មូលនិធិអភិវឌ្ឍន៍ភូមិ,បន្ធូរបន្ថយបំណុលសម្រាប់កសិករ។ គោលនយោបាយទាំងនេះទទួលបានការគាំទ្រយ៉ាងច្រើនពីសហគមន៍ជនបទនិងបានពង្រឹងមូលដ្ឋានអំណាចរបស់លោកថាក់ស៊ីន។ គោលនយោបាយដឹកនាំភាពជាបុរសខ្លាំងលោកថាក់ស៊ីនបានសង្កត់ធ្ងន់ទៅលើអភិបាលកិច្ចកណ្តាលនិង «ការគ្រប់គ្រងតាមទម្រង់បែបជានាយកប្រតិបត្តិជារបៀបក្រុមហ៊ុន(CEO)[2]។ ទន្ទឹមនឹងមានការសាទរលោកក៏មានដែរការតិះទៀតដោយអ្នករិះគន់បានចោទប្រកាន់គាត់ពីទំនោរផ្តាច់ការនិងធ្វើឱ្យប៉ះពាល់ដល់ការត្រួតពិនិត្យនិងតុល្យភាពនៃការដឹកនាំ។ ជាមួយគ្នានេះលោកថាក់ស៊ីនក៏បានបង្ក្រាប

---

1 Hughes, Caroline. “Cambodia and Thailand: Diplomacy, Nationalism and the Border Conflict.” Contemporary Southeast Asia 25, no. 3 (2003): 460–478.

2 Duncan McCargo, ‘Toxic Thaksin? Thailand’s troublesome ex-premier’, Representation, 47, 3, 2011: 295–306.

ប្រព័ន្ធផ្សព្វផ្សាយនិងក្រុមប្រឆាំងនឹងគណបក្សក៏ដូចជារូបលោកផ្ទាល់។ចំណុចនេះក៏ត្រូវបានគេកត់សម្គាល់ និងមានការព្រួយបារម្ភកាន់តែខ្លាំងឡើងលើការចាប់ពិរុទ្ធប្រព័ន្ធផ្សព្វផ្សាយ។ រីឯសំឡេងឯករាជ្យប្រឈមមុខនឹងសម្ពាធកើនឡើងខណៈដែលរដ្ឋាភិបាលរបស់លោកថាក់ស៊ីនត្រូវបានចោទប្រកាន់ថាបានប្រើប្រាស់ថវិកាផ្សាយពាណិជ្ជកម្មនិងឧបករណ៍និយតកម្មដើម្បីបំបិទមាត់អ្នករិះគន់។

## ១.២. សង្គ្រាមលើគ្រឿងញៀន

សង្គ្រាមគ្រឿងញៀនរបស់លោកថាក់ស៊ីនហាក់បានបង្ហាញពីទិដ្ឋភាពដ៏ចម្រូងចម្រាសបំផុតមួយនៃគោលនយោបាយក្នុងស្រុករបស់ថាក់ស៊ីនក្នុងឆ្នាំ ២០០៣ផងដែរ។ យុទ្ធនាការប្រឆាំងគ្រឿងញៀនដ៏ខ្លាំងក្លារបស់គាត់ដែលបានចាប់ផ្តើមនៅក្នុងខែកុម្ភៈ ឆ្នាំ ២០០៣ ក្នុងនោះមនុស្សជាង២,៨០០នាក់ត្រូវបានរាយការណ៍ថាបានសម្លាប់ក្នុងរយៈពេលបីខែដំបូងដែលជាការសម្លាប់ក្រៅប្រព័ន្ធតុលាការ[1]។ ប្រឈមនឹងការរិះគន់រដ្ឋាភិបាលបានអះអាងថា អ្នកទាំងនេះភាគច្រើនជាអ្នកជួញដូរគ្រឿងញៀនដែលត្រូវបានសម្លាប់នៅក្នុងការបាញ់ប្រហារក៏ដោយក៏ក្រុមសិទ្ធិមនុស្សនិងអ្នកសង្កេតការណ៍អន្តរជាតិបានចង្អុលបង្ហាញពីការរំលោភបំពានយ៉ាងទូលំទូលាយនិងកង្វះដំណើរការត្រឹមត្រូវឬប្រើឡេសនេះដើម្បីកំតេចអ្នកប្រឆាំងនឹងលោក។យុទ្ធនាការដំបូងទទួលបានការគាំទ្រយ៉ាងខ្លាំងពីសាធារណជនប៉ុន្តែការរិះគន់អន្តរជាតិកាន់តែខ្លាំងជាពិសេសពីអង្គការសហប្រជាជាតិ និងអង្គការលើកលែងទោសអន្តរជាតិ។

## ១. ៣. ជាតិនិយមថៃ និងកុបកម្មកម្ពុជា

ក្រោយកុប្បកម្មនៅខែមករា ឆ្នាំ២០០៣ ចលនាជាតិនិយមនៅថៃបានកើនឡើងក្នុងប្រទេសថៃ។គេមើលឃើញថាលោកថាក់ស៊ីនបានប្រើឧប្បត្តិហេតុនេះដើម្បីបញ្ចាំងរូបភាពអ្នកការពារដោយទាមទារការសុំទោសនិងសំណងពីខាងកម្ពុជា

1 Human Rights Watch. Thailand's "War on Drugs". New York: Human Rights Watch, 2004.

ដើម្បីកេងចំណេញលើទិដ្ឋភាពនយោបាយនិងជាតិនិយម។ ម្យ៉ាងវិញទៀតកុបកម្មក៏បានជួយបង្វែរពីភាពចលាចលក្នុងស្រុកដែលកំពុងកើនឡើងជុំវិញសេរីភាពសារព័ត៌មាន និងការរំលោភបំពានរបស់ពលរដ្ឋថៃផងដែរ។

ជារួមមកការកាន់តំណែងរបស់លោកថាក់ស៊ីនមិនបានយូរឡើយដោយលោកត្រូវបានយោធាធ្វើរដ្ឋប្រហារផ្តួលរំលំរូបលោកនៅឆ្នាំ២០០៦ក្រោមរូបភាពអស្ថេរភាពក្នុងថៃ ព្រោះម្យ៉ាងទៀតប្រជាប្រិយភាពរបស់លោកជាការបារម្ភមួយជាការគំរាមកំហែងដល់អំណាចយោធានិងរាជវាំងថៃទន្ទឹមនឹងនេះក៏មានគេមើលឃើញថាក្រោយពីការប្រមាថដល់បុព្វបុរសខ្មែរនៅប្រាសាទអង្គរវត្តដែលជាកន្លែងសក្តិសិទ្ធិនិងជានិមិតរូបរបស់កម្ពុជាមិនអាចមើលស្រាលឬលេងសើចបាននោះឡើយ។

## ២. លោកស្រីយីងឡាក់ស៊ីណាវ៉ាត្រា និងជម្លោះប្រាសាទព្រះវិហារ (២០១១-២០១៤)

ក្រោយពេលលោកថាក់ស៊ីន ត្រូវបានគេបណ្តេញចេញពីតំណែងឥទ្ធិពលរបស់លោកថាក់ស៊ីនបានវិលមកវិញសាជាថ្មី គ្រាន់តែលើកនេះជាសាច់ឈាមរបស់គាត់វិញម្តង គឺប្អូនស្រីរបស់លោកថាក់ស៊ីន គឺលោកស្រី យីងឡាក់ ស៊ីណាវ៉ាត្រា។ ជាការពិតណាស់ ការឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីរបស់លោកស្រី យីងឡាក់ ស៊ីណាវ៉ាត្រាស្របពេលសភាពការនៅទល់ដែនកម្ពុជា-ថៃមានការប្រែប្រួលខ្លាំងបំផុតជុំវិញជម្លោះប្រាសាទព្រះវិហារ។កាលពីសម័យបងប្រុសរបស់លោកស្រីក៏មានបញ្ហាជាតិនិយមជាមួយកម្ពុជាដែរ គឺជុំវិញប្រាសាទអង្គរវត្ត ប៉ុន្តែនៅក្នុងសម័យសលោកស្រីយីងឡាក់ស៊ីណាវ៉ាត្រាគឺមានបញ្ហាជុំវិញប្រាសាទព្រហវិហារវិញម្តង។ ត្បិតតែតុលាការយុត្តិធម៌អន្តរជាតិ (ICJ) បានសម្រេចនៅឆ្នាំ១៩៦២ថាប្រាសាទព្រះវិហារជាកម្មសិទ្ធិរបស់ប្រទេសកម្ពុជាក៏ដោយក៏ជម្លោះជុំវិញទឹកដីនៅតែកើតមានដដែល។

ក្នុងពេលចូលកាន់តំណែងរបស់លោកស្រីយីងឡាក់ ចលនាជាតិនិយមនិងផ្ទៃក្នុងថៃនៅតែបន្តមានភាពរំជើបរំជួលហើយ បញ្ហាជាតិនិយមក៏នៅតែជាប្រធានបទក្ដៅសម្រាប់អ្នកនយោបាយថៃប្រើដដែលគឺក្នុងចេតនាដើម្បីបង្វែរស្ថានការណ៍ផ្ទៃក្នុងខ្លួន,និងដើម្បីទាញចំណាប់អារម្មណ៍ពីពលរដ្ឋឱ្យងាកមករួមចំណែកជាមួយរដ្ឋាភិបាលខ្លួនក្នុងការការពារទឹកដី។ពេលនោះក្នុងឆ្នាំ២០១១ តុលាការយុត្តិធម៌អន្តរជាតិ(ICJ)បានយល់ព្រមបកស្រាយឡើងវិញនូវសេចក្ដីសម្រេចដើមដែលបង្កឱ្យមានភាពតានតឹងផ្នែកយោធាជាថ្មីនៅតាមព្រំដែនរវាងកម្ពុជានិងថៃ។ មិនខុសពីលើកមុនដែរគឺថៃរងភាពអាម៉ាសសារជាថ្មីម្ដងទៀតលើឆាកអន្តរជាតិចំពោះបញ្ហាព្រះសាទព្រះវិហារ។ ស្ថានភាពនោះជាហេតុនាំលោកស្រីយីងឡាក់បានប្រឈមមុខនឹងការរិះគន់យ៉ាងខ្លាំងចំពោះទំនាក់ទំនងជិតស្និទ្ធរបស់លោកស្រីជាមួយនឹងកម្ពុជា។ ដោយក្រុមប្រឆាំងរដ្ឋាភិបាលលោកស្រីយីងឡាក់ចោទថា អតីតនាយករដ្ឋមន្ត្រីថាក់ស៊ីន ដែលនៅពេលនោះត្រូវបានកាត់ទោសនិងរស់នៅនិរទេសត្រូវបានកម្ពុជាតែងតាំងជាទីប្រឹក្សាសេដ្ឋកិច្ចពិសេសរបស់កម្ពុជា។ សកម្មភាពនេះនាំឱ្យផ្ទៃក្នុងថៃមានភាពចម្រូងចម្រាសដែលនាំឱ្យមានការចោទប្រកាន់ថាលោកស្រីយីងឡាក់កំពុងបំពានអធិបតេយ្យភាពជាតិ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួននិងសេដ្ឋកិច្ចរបស់បងប្រុសលោកស្រី។

ម្យ៉ាងវិញទៀត រដ្ឋបាលរបស់លោកស្រីត្រូវបានគេចោទប្រកាន់ថាខ្សោយក្នុងការដឹកនាំពិសេសចំពោះការការពារទឹកដី[(1)]។ ភាពតានតឹងទាំងនេះត្រូវបានពង្រីកនៅក្នុងប្រព័ន្ធផ្សព្វផ្សាយថៃដោយផ្ដល់នូវការនិទានរឿងជាតិនិយមដែលបានធ្វើឱ្យខូចដល់ភាពស្របច្បាប់របស់លោកស្រីយីងឡាក់ស៊ីណាវ៉ាត្រា។ នៅទីបំផុតទៅរដ្ឋាភិបាលោកស្រីយីងឡាក់ក៏មានវាសនាដូចគ្នានឹងបងប្រុសរបស់គាត់ដែរ។ លទ្ធផលចុងក្រោយ គឺត្រូវបានយោធាធ្វើរដ្ឋប្រហារដែលដឹកនាំដោយលោកប្រាយុទ្ធច័ន្ទអូចា

1 Pathmanand, Ukrist. "The Thai-Cambodian Temple Dispute: The Domestic Politics of Border Demarcation." Asian Survey 51, no. 6 (2011): 1019–1042.

នៅឆ្នាំ២០១៤។ដូច្នេះបញ្ហាជាតិនិយមនៅថៃជារឿងផ្ទៃក្នុងនៅនយោបាយរបស់ខ្លួនហើយការទាញកម្ពុជាឱ្យចូលក្នុងវិបត្តខ្លួនតាមរយៈជម្លោះព្រំដែននិងប្រាសាទបុរាណកម្ពុជាគឺជាទ្វេរគ្រោះខ្លួនឯង ចុងក្រោយគឺរដ្ឋាភិបាលថៃខ្លួនឯង ត្រូវបានជាអ្នកទទួលផលអវិជ្ជមានដោយត្រូវគេធ្វើរសដ្ឋប្រហារ។

## ៣. រដ្ឋាភិបាលលោកស្រីផែថោងថាន (កូនស្រីលោកថាក់ស៊ីន) និងភាពតានតឹងព្រំដែនឆ្នាំ ២០២៥

គិតត្រឹមពាក់កណ្តាលឆ្នាំ ២០២៥ អ្នកស្រី Paetongtarn Shinawatra ដែលជាកូនស្រីរបស់លោកថាក់ស៊ីននិងជាមេដឹកនាំបច្ចុប្បន្ននៃគណបក្សភឿថៃប្រឈមមុខនឹងស្ថានភាពថ្មីលើសំណុំរឿងចាស់ជុំវិញបញ្ហាព្រំដែនកម្ពុជា-ថៃ។ ឧបទ្ទវហេតុនៃការបាញ់ប្រហារកាលពីថ្ងៃទី២៨ខែឧសភាឆ្នាំ២០២៥ត្រូវបានគេរាយការណ៍នៅជិតតំបន់ប្រទាញប្រទង់នៅតាមព្រំដែនតាមជួរភ្នំដងរែកដែលជំរុញឱ្យមានការព្រួយបារម្ភនៃជម្លោះបន្តទៀត។

ស្ថានភាពនេះ ក៏ជាសញ្ញាណនៃការបែកបាក់ផ្ទៃក្នុង ព្រោះថារដ្ឋាភិបាលចម្រុះថៃហាក់ដល់ផ្លូវបំបែករវាងគណបក្សភឿថៃរបស់លោកស្រីផែថោងថាននិងក្រុមយោធា។ ពិសេសការលូកដៃចូលជ្រៅរបស់លោកថាក់ស៊ីននៅក្នុងនយោបាយថៃក៏ជាហេតុផលមួយនៅក្រោយបញ្ហានេះដែរ។

ជាមួយគ្នានេះ អ្នកនយោបាយជាតិនិយមថៃបានទាញបញ្ហាផ្ទៃក្នុងខ្លួនមកជំពាក់ជំពិនជាមួយកម្ពុជាដោយរំលេចឱ្យឃើញពីចេតនាមិនល្អរបស់ខ្លួនជុំវិញអធិបតេយ្យភាពកម្ពុជានៅតំបន់មុំបី,ប្រាសាទតាមាន់តូច,ប្រាសាទតាមាន់ធំនិងប្រាសាទតាក្របី។ ជាសេនារីយោជដែលៗរបស់ថៃ ពេលនេះក៏ដូចគ្នាទៅនឹងកាលពីការដឹកនាំរបស់លោកថាក់ស៊ីន និងលោកស្រីយីងឡាក់អញ្ចឹងដែរ។

ជាការឆ្លើយតបរបស់កម្ពុជាពីជំហររបស់ខ្លួនកម្ពុជាបានចេញបីសេនារីយោ គឺទី១.បញ្ជូនកងទ័ពនិងគ្រឿងយុទ្ធោបករណ៍ជាច្រើនទៅកាន់តំបន់ជម្លោះនិងតាមខ្សែបន្ទាត់ព្រំដែន,ទី២.នយោបាយការទូតកម្ពុជាបានកោះប្រជុំវត្តមានអគ្គទូតទាំង២៧ដែលមានវត្តមាននៅកម្ពុជាដើម្បីពន្យល់ពីស្ថានការណ៍នៅព្រំដែនកម្ពុជា-ថៃ[1],កម្ពុជារក្សាជំហរការជួយបប្រជុំរបស់ក្រុមការងារកិច្ចការព្រំដែនរវាងប្រទេសទាំងពីរ[2] និងទី៣.កម្ពុជាបានប្តឹងករណីនេះទៅកាន់តុការលាការយុត្តិធម៌អន្តរជាតិ[3]។ក្រៅពីនេះកម្ពុជាក៏មានផងដែរការប្រកាសពហិការឈប់ប្រើទំនិញថៃ,បិទការនាំចូលបន្លែនិងផ្លែឈើរបស់ថៃនិងបានរឹតបន្តឹងតាមច្រកព្រំដែនរវាងប្រទេសទាំងពីរថែមទៀតផង។ជំហររបស់រាជរដ្ឋាភិបាលកម្ពុជាបានពេលនេះត្រូវបានការសាទរពីប្រជាពលរដ្ឋកម្ពុជាពេញផ្ទៃប្រទេស។

នៅចំពោះមុខស្ថានការណ៍ដ៏តានតឹងនៅពេលនេះយើងរង់ចាំមើលបន្តទៀតថាតើនោយបាយជាតិនិយមដែលថៃកំពុងអនុវត្តនាពេលនេះ នឹងប្រប្រួលទៅជាយ៉ាងណាក្នុងពេលអនាគតដ៏ខ្លីខាងមុខនេះ?តើពលរដ្ឋថៃនិងអ្នកនយោបាយជ្រុលនិយមរបស់ថៃនឹងរុញសភាពការណ៍ទៅជាអ្វីថ្មីទៀតតើពួកគេបន្តជំរុញឱ្យមានការប៉ះទង្គិចដោយយោធាសារជាថ្មីទៀតឬរុញសភាពការណ៍ដើម្បីធ្វើរដ្ឋប្រហារទំលាក់លោកស្រីផែថោងថាន?

1 Sim Chansamnang. "ប្រមុខការទូតកម្ពុជាជួបជាមួយអគ្គទូតបរទេសចំនួន ២៧ ដើម្បីពន្យល់ពីស្ថានការណ៍ជម្លោះព្រំដែនខ្មែរ-ថៃ." RFI Khmer, June 17, 2025. https://www.rfi.fr/km/20250617-ប្រមុខការទូតកម្ពុជាជួបជាមួយអគ្គទូតបរទេសចំនួន២៧-ដើម្បីពន្យល់ពីស្ថានការណ៍ជម្លោះព្រំដែនខ្មែរ-ថៃ. Accessed June 17, 2025.

2. អង្គភាពប្រតិកម្មរហ័ស. «សមាជរដ្ឋសភា និងព្រឹទ្ធសភា គាំទ្រចំណាត់ការរបស់រាជរដ្ឋាភិបាលកម្ពុជាលើបញ្ហាព្រំដែន ជាមួយព្រះរាជាណាចក្រថៃក្រោយហេតុការណ៍វាយប្រហារប្រដាប់អាវុធនៅតំបន់មុំបីក្នុងទឹកដីកម្ពុជា.» Office of the Council of Ministers (Cambodia), June 3, 2025. https://pressocm.gov.kh/archives/111004. Accessed June 17, 2025.

3. Sam Uddom. "ជម្លោះព្រំដែនកម្ពុជា-ថៃ៖ រដ្ឋាភិបាលកម្ពុជាបង្កើតគណៈកម្មការរៀបចំបណ្តឹងដើម្បីប្តឹងថៃទៅ ICJ." RFI Khmer, June 11, 2025. https://www.rfi.fr/km/.... Accessed June 17, 2025.

# សេចក្តីសន្និដ្ឋាន

ជារួមមក ចាប់តាំងពីឆ្នាំ២០០៣ដល់២០២៥នេះ អ្នកនយោបាយជាតិនិយមជ្រុលរបស់ថៃតែងប្រើប្រាស់សេនារីយោជាតិនិយមដើម្បីបង្វែរស្ថានការណ៍នយោបាយផ្ទៃក្នុងរបស់ខ្លួន មកលើបញ្ហាព្រំដែនរវាងកម្ពុជានឹងថៃ ដើម្បីជាចេតនាផុតពេលជាតិនិយមផង,និងដើម្បីដាក់បន្ទុកទំលាក់កំហុសមកលើរដ្ឋាភិបាលថៃខ្លួនឯងផងដើម្បីបន្តសេនារីយោបន្ទាប់គឺប្រើប្រាស់កម្លាំងយោធាក្នុងការផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់ ហើយភាគច្រើនគឺនៅក្រោមការដឹកនាំរបស់គ្រួសារត្រកូលថាក់ស៊ីន ដែលមានដូចជា សម័យថាក់ស៊ីន ស៊ីណាវ៉ាត្រា, បន្តដោយយីងឡាក់ស៊ីណាវ៉ាត្រា ហើយបច្ចុប្បន្ននេះកូនស្រីលោកថាក់ស៊ីមគឺលោកស្រី ផែថោងថាន់ ក៏មានបញ្ហាជម្លោះព្រំដែនជាមួយកម្ពុជាផងដែរគិតត្រឹម( ១៧ មិថុនា ២០២៥)។

តាមរយៈបទពិសោធនាពេលកន្លងមកគឺជំហររាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា តែងប្រើប្រាស់នយោបាយដែលមានភាពចាស់ទុំច្រើនជាងប្រទេសថៃ ដោយប្រើទាំងវិធីសាស្ត្ររឹងនិងទន់ មានន័យថាកម្ពុជាប្រើនយោបាយការទូត,យន្តការច្បាប់អន្តរជាតិ,និងកម្លាំងយោធាដើម្បីរក្សាការពារនូវអធិបតេយ្យភាពរបស់ខ្លួនទល់នឹងជម្លោះព្រំដែនកម្ពុជាថៃហើយកម្ពុជាតែងទទួលបាននូវការគាំទ្រពីប្រជាពលរដ្ឋខ្លួននិងលើឆាកអន្តរជាតិ ។

យើងឃើញថាអ្នកដែលប៉ុនប៉ងចង់បានប្រាសាទកម្ពុជាតែងទទួលផលកម្មមកលើខ្លួនឯងជានិច្ច,ចុះនៅពេលខាងមុខនេះវិញ តើជោគវាសនានៃរដ្ឋាភិបាលកូនស្រីលោកថាក់ស៊ីននឹងទៅជាយ៉ាងណានៅចំពោះចំណាត់ការតបតរបស់កម្ពុជាជុំវិញបញ្ហាព្រំដែនជាមួយកម្ពុជាក្នុងឆ្នាំ២០២៥នេះ?តើលោកអ្នកអានយល់ថាបារមីបុព្វបុរសខ្មែរនៅតែមានឬទេដែលកំពុងតាមថែរក្សារាជរដ្ឋាភិបាលកម្ពុជា,ថែរក្សាទឹកដីកម្ពុជានិងប្រជាជនកម្ពុជា? យើងតាមដានការវិវត្តថ្មីៗបន្តទៅទៀត... !!!!

# ឯកសារពិគ្រោះ


1. Aglionby, John. "Thais Cut Links with Cambodia after Riots." The Guardian, January 31, 2003. https://www.theguardian.com/world/2003/jan/31/cambodia. Accessed June 17, 2025.
2. DAWN. "Cambodians Attack Thai Embassy." DAWN, January 30, 2003. https://www.dawn.com/news/79958/cambodians-attack-thai-embassy. Accessed June 17, 2025.
3. Human Rights Watch. Thailand's "War on Drugs." New York: Human Rights Watch, 2004.https://www.hrw.org/report/2004/06/07/thailands-war-drugs. Accessed June 17, 2025.
4. Hughes, Caroline. "Cambodia and Thailand: Diplomacy, Nationalism and the Border Conflict." Contemporary Southeast Asia 25, no. 3 (2003): 460–478.
5. LinkedIn. "13 Years Have Passed: My Escape From Phnom Penh." By Daniel Malloy. LinkedIn, December 14, 2016.https://www.linkedin.com/pulse/13-years-have-passed-my-escape-from-phnom-penh-pavin-chachavalpongpun. Accessed June 17, 2025.
6. McCargo, Duncan. "Toxic Thaksin? Thailand's Troublesome Ex-Premier." Representation 47, no. 3 (2011): 295–306.
7. Paddock, Richard C. "Rumor of Thai Actress' Words Salted a Wound." Los Angeles Times, February 3, 2003.https://www.latimes.com/archives/la-xpm-2003-feb-03-fg-cambo3-story.html. Accessed June 17, 2025.
8. Pathmanand, Ukrist. "The Thai-Cambodian Temple Dispute: The Domestic Politics of Border Demarcation." Asian Survey 51, no. 6 (2011): 1019–1042.
9. The diplomat. "The Actress, the Temple, and the Alleged Remark That Brought Two Nations to the Brink of War." The Independent, January 31, 2003.https://www.independent.co.uk/news/world/asia/the-actress-the-temple-and-the-alleged-remark-that-brought-two-nations-to-the-brink-of-war-5352428.html. Accessed June 16, 2025.
10. Sam Uddom. "ជម្លោះព្រំដែនកម្ពុជា-ថៃ៖ រដ្ឋាភិបាលកម្ពុជាបង្កើតគណៈកម្មការរៀបចំបណ្ដឹងដើម្បីប្ដឹងថៃទៅ ICJ." RFI Khmer, June 11, 2025.
11. https://www.rfi.fr/km/20250611-ជម្លោះព្រំដែនកម្ពុជា-ថៃ-រដ្ឋាភិបាលកម្ពុជាប្ដឹងថៃ-ICJ. Accessed June 17, 2025.
12. Sim Chansamnang. "ប្រមុខការទូតកម្ពុជាជួបជាមួយអ្នកទូតបរទេសចំនួន ២៧ ដើម្បីពន្យល់ពីស្ថានការណ៍ជម្លោះព្រំដែនខ្មែរ-ថៃ." RFI Khmer, June 17, 2025. https://www.rfi.fr/km/20250617-ប្រមុខការទូតកម្ពុជាជួបជាមួយអ្នកទូតបរទេសចំនួន២៧-ដើម្បីពន្យល់ពីស្ថានការណ៍ជម្លោះព្រំដែនខ្មែរ-ថៃ. Accessed June 17, 2025.
13. អង្គភាពប្រតិកម្មរហ័ស. "សមាជិករដ្ឋសភា និងព្រឹទ្ធសភា គាំទ្រចំណាត់ការរបស់រាជរដ្ឋាភិបាលកម្ពុជាលើបញ្ហាព្រំដែន ជាមួយព្រះរាជាណាចក្រថៃក្រោយហេតុការណ៍វាយប្រហារប្រដាប់អាវុធនៅតំបន់មុំបីក្នុងទឹកដីកម្ពុជា." Office of the Council of Ministers (Cambodia), June 3, 2025.https://pressocm.gov.kh/archives/111004. Accessed June 17, 2025.